**ចំណាប់អារម្មណ៍គន្លឹះ**

**របស់អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**ឧបនាយករដ្ឋមន្ត្រី, រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**ថ្លែងក្នុង**

**សិក្ខាសាលាស្តីពីការឈ្វេងយល់អំពី**

**ការកសាងក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និង គោលនយោបាយហិរញ្ញវត្ថុសាធារណៈ សម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២០**

**វិមានរដ្ឋសភា, ថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០១៩**

***ខ្ញុំបានសូមគោរពសម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពដ៏ខ្ពង់ខ្ពស់ !***

***ខ្ញុំសូមគោរព ÷***

- ***ឯកឧត្តម អនុប្រធាន នៃព្រឹទ្ធសភា និង រដ្ឋសភា;***
- ***លោកជំទាវ អគ្គសវនករ នៃអាជ្ញាធរសវនកម្មជាតិ;***
- ***ឯកឧត្តម, លោកជំទាវ, ប្រធាន អនុប្រធាន នៃគណៈកម្មាការ, សមាជិក-សមាជិកា នៃព្រឹទ្ធសភា និង រដ្ឋសភា;***
- ***ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី, ភ្ញៀវជាតិ និង អន្តរជាតិ ជាទីមេត្រី !***

តាងនាមឱ្យរាជរដ្ឋាភិបាល, រូបខ្ញុំ និង សហការី មកពីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ, ពិតជាមានកិត្តិយស និង ក្តីសោមនស្ស ជាអនេក ដោយបានទទួលការអញ្ជើញចូលរួមក្នុង **សិក្ខាសាលាស្តីពីការកសាង**

**ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និង គោលនយោបាយហិរញ្ញវត្ថុសាធារណៈ សម្រាប់ការរៀបចំសេចក្ដី-ព្រាងច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២០** ដែលប្រព្រឹត្តទៅក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ របស់ **សម្ដេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា** នាពេលនេះ ។

យើងខ្ញុំសូមសំដែងនូវកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅបំផុត គោរពជូនចំពោះ **សម្ដេចអគ្គមហាពញា-ចក្រី ហេង សំរិន ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា** ដែលបានផ្ដល់ឱកាសដល់យើងខ្ញុំទាំងអស់គ្នា, ជាថ្នាក់ដឹកនាំនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ, ទាំងកម្រិតនយោបាយ និង កម្រិតបច្ចេកទេស, ចែករំលែកនូវព័ត៌មាន និង ការយល់ដឹងអំពីស្ថានការណ៍ និង ការរៀបចំក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និង គោលនយោបាយហិរញ្ញវត្ថុសាធារណៈ ដែលជាមូលដ្ឋានសម្រាប់ការរៀបចំថវិកាជាតិ ឆ្នាំ ២០២០ ជូនសម្ដេច, ឯកឧត្ដម, លោកជំទាវ, ជាសមាជិក, សមាជិកា, នៃព្រឹទ្ធសភា និង រដ្ឋសភា ។

ទន្ទឹមនេះដែរ, អង្គសិក្ខាសាលានាថ្ងៃនេះ គឺជាវេទិកាមួយដ៏មានសារៈសំខាន់ សម្រាប់បន្តចូលរួមលើកកម្ពស់តម្លាភាពថវិកា និង កិច្ចសន្ទនារវាងស្ថាប័ននីតិប្បញ្ញត្តិ និង ស្ថាប័ននីតិប្រតិបត្តិ ព្រមទាំងតួអង្គពាក់ព័ន្ធទាំងអស់ ឈ្វេងយល់កាន់តែលម្អិត និង ទូលំទូលាយ អំពីការគិតគូរ និង កសាងក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និង គោលនយោបាយហិរញ្ញវត្ថុសាធារណៈ ប្រចាំឆ្នាំរបស់រាជរដ្ឋាភិបាល ។ លើសពីនេះទៀត, សិក្ខាសាលានេះ ក៏ជាការបើកឡើងនូវឱកាសដ៏កម្រ ដើម្បីពិភាក្សាអំពីការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយជាអាទិភាពរបស់រាជរដ្ឋាភិបាល សំដៅសម្រេចឱ្យបាននូវគោលដៅជាយុទ្ធសាស្ត្ររបស់ជាតិ ដើម្បីឆ្លើយតបទៅនឹងឆន្ទៈ និង បំណងប្រាថ្នារបស់ប្រជាជនកម្ពុជា ។ ក្នុងស្មារតីនេះ, រូបខ្ញុំ និងសហការី បានត្រៀមខ្លួនជាស្រេច ក្នុងការទទួលយកនូវអនុសាសន៍ល្អៗ ជាធាតុចូលបន្ថែមពីអង្គសិក្ខាសាលា ដើម្បីឱ្យការរៀបចំក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និង គោលនយោបាយហិរញ្ញវត្ថុសាធារណៈរបស់ជាតិ កាន់តែមានលក្ខណៈប្រសើរឡើងថែមទៀត នៅក្នុងឆ្នាំបន្តបន្ទាប់ខាងមុខ ។

អាស្រ័យដោយឯកឧត្តមបណ្ឌិតរដ្ឋ **ជាម យៀប**, ប្រធានគណៈកម្មការទី ២ នៃរដ្ឋសភា, បានលើកឡើងយ៉ាងក្បោះក្បាយរួចហើយ អំពីស្ថានភាពគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និង គោលនយោបាយហិរញ្ញវត្ថុសាធារណៈ ពិសេស សម្រាប់ឆ្នាំ ២០២០ ហើយសហការីរបស់ខ្ញុំ ក៏នឹងធ្វើបទបង្ហាញលម្អិតថែមទៀតជូនដល់អង្គសិក្ខាសាលា បន្ទាប់ពីកម្មវិធីបើកនេះ, ដូច្នេះ នាពេលនេះ ខ្ញុំសូមគូសរំលេចដោយសង្ខេប ជូនអង្គ-

សិក្ខាសាលា នូវចំណុចសំខាន់ៗចំនួន ៤ តែប៉ុណ្ណោះ រួមមាន : (១). សមិទ្ធកម្មម៉ាក្រូសេដ្ឋកិច្ច ចាប់តាំងពីដើមនីតិកាលទី ៦ នេះ ដែលកើតចេញពីកិច្ចខិតខំប្រឹងប្រែង និង ឆន្ទៈមោះមុតឥតរាថយរបស់រាជរដ្ឋាភិបាល; (២). បញ្ហាប្រឈម គួបផ្សំនឹងហានិភ័យ ចំពោះការអភិវឌ្ឍកម្ពុជា; (៣). ទិសដៅអាទិភាពរបស់រាជរដ្ឋាភិបាល នៅក្រោមក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និង គោលនយោបាយហិរញ្ញវត្ថុសាធារណៈប្រចាំឆ្នាំ ២០២០; និង (៤). វឌ្ឍនភាពសំខាន់ៗ នៅក្នុងការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

ខ្ញុំសូមឆ្លងចូលទៅធ្វើការអធិប្បាយដោយខ្លីៗ លើចំណុចនីមួយៗ ដូចខាងក្រោម ÷

### ទី១. សមិទ្ធកម្មម៉ាក្រូសេដ្ឋកិច្ច ចាប់តាំងពីដើមនីតិកាលទី ៦

ក្រោមការដឹកនាំដ៏ត្រឹមត្រូវ ប្រកបដោយគតិបណ្ឌិត របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ក្នុងការអនុវត្តគោលនយោបាយ ដូចមានចែងក្នុង **យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤** និង ស្របតាមបាវចនា ២ គឺ: **«កែទម្រង់ខាងក្នុង និង បង្កើនមិត្តខាងក្រៅ ដោយឈរលើស្មារតីឯករាជ្យ»**, កម្ពុជាបន្តរក្សាបាននូវសន្តិភាព, សន្តិសុខ, ស្ថិរភាពនយោបាយ និង ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និង ហិរញ្ញវត្ថុរឹងមាំ, ដែលទាំងអស់នេះ គឺជាមូលដ្ឋានមិនអាចខ្វះបាន សម្រាប់ការអភិវឌ្ឍប្រទេស ។ ការណ៍នេះ សបញ្ជាក់ឱ្យឃើញយ៉ាងប្រត្យក្ស ពីការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាល ក្នុងការរក្សាការពារសមិទ្ធផលដែលសម្រេចបាន ក្នុងរយៈពេលជាង ២ ទសវត្សរ៍កន្លងមកនេះ និង ក្នុងការបន្តខិតខំសម្រេចឱ្យបាននូវគោលដៅជាអាទិភាពថ្មីៗទៀត ជូនប្រជាជនកម្ពុជា ស្របតាម **កម្មវិធីនយោបាយ** របស់ខ្លួន ។

ជាក់ស្តែង, នៅក្នុងឆ្នាំ ២០១៨, អត្រាកំណើនសេដ្ឋកិច្ចរបស់កម្ពុជា សម្រេចបាន ៧,៥% ដែលជាកំណើនមួយខ្ពស់បំផុត ក្នុងរយៈពេល ១០ ឆ្នាំចុងក្រោយ ។ ទន្ទឹមនេះ, អត្រាអតិផរណាមធ្យមប្រចាំឆ្នាំ ត្រូវបានគ្រប់គ្រងឱ្យស្ថិតនៅក្នុងកម្រិតទាប ប្រមាណ ២,៥% ។ នៅក្នុងឆ្នាំ ២០១៨ កន្លងទៅ, ចំណូលចរន្តថវិកាជាតិមានការកើនឡើងល្អប្រសើរ ក្នុងអត្រាប្រមាណ ២០,៤% ដែលធ្វើឱ្យចំណូលចរន្តនៃថវិកាជាតិ មានទំហំស្មើនឹងប្រមាណ ២១,៩៦% នៃ ផសស ។ លទ្ធផលនេះ សម្រេចបានមក ដោយសារភាពមមាញឹកនៃសកម្មភាពអាជីវកម្មក្នុងស្រុក និង សមិទ្ធផលបណ្តើរៗ ពីការងារកែទម្រង់សំដៅបង្កើនប្រសិទ្ធភាពនៃរដ្ឋបាលសារពើពន្ធ

ព្រមទាំងពីការកើនឡើងនៃការយល់ដឹងពីវប្បធម៌បង់ពន្ធ ។ **បើធៀបនឹង ផសស, នៅក្នុងឆ្នាំ ២០១៨ អត្រាចំណូលចរន្តថវិកាជាតិ សម្រេចបានកំណើនរហូតដល់ ១,៩ ពិន្ទុភាគរយនៃ ផសស ដែលលើសជាងមួយជាបីដង ធៀបនឹងគោលដៅ ០,៥ ពិន្ទុភាគរយនៃ ផសស ជាមធ្យមក្នុងមួយឆ្នាំ កំណត់នៅក្នុងយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម សម្រាប់ឆ្នាំ ២០១៤-២០១៨ ។**

សម្រាប់ឆ្នាំ ២០១៩ នេះ, សេដ្ឋកិច្ចកម្ពុជា ត្រូវបានប៉ាន់ស្មានថា នឹងបន្តសម្រេចបានកំណើនខ្ពស់ ក្នុងរង្វង់ប្រមាណ ៧,១% ដោយសារកំណើនខ្ពស់នៃការនាំចេញ ជាពិសេស ផលិតផលកាត់ដេរ, ការបន្តកំណើនរឹងមាំនៃការវិនិយោគលើវិស័យសំណង់ និង ការរីកធំធាត់នៃការប្រើប្រាស់ក្នុងស្រុក ។ ទន្ទឹមនេះ, អត្រាអតិផរណា ក៏នឹងបន្តស្ថិតក្នុងកម្រិតទាប ក្រោម ៣% ។ **ចំណូលក្នុងស្រុក ត្រូវបានរំពឹងថា នឹងអាចសម្រេចបានលើសផែនការ ដែលក្នុងនេះ ចំណូលចរន្តថវិកាជាតិ សម្រាប់រយៈពេល ៦ ខែដើមឆ្នាំ សម្រេចបានប្រមាណ ៥៨,៨% រួចហើយ ធៀបទៅនឹងគោលដៅប្រចាំឆ្នាំ ។** ការណ៍នេះ សបញ្ជាក់ឱ្យឃើញពីភាពរឹងមាំនៃសេដ្ឋកិច្ចកម្ពុជា, ទោះបីជាសេដ្ឋកិច្ចពិភពលោក បន្តប្រឈមនឹងហានិភ័យកាន់តែច្រើនជាងមុនក៏ដោយ ។

ទន្ទឹមនេះ, ក្រោមមគ្គុទ្ទេសក៍ដ៏ឈ្លាសវៃ ប្រកបដោយភាពប្រាកដនិយម របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា,** រាជរដ្ឋាភិបាលបានសម្រេចដាក់ចេញ និង ជំរុញអនុវត្តវិធានការមុតស្រួច ជាកញ្ចប់ សំដៅពន្លឿនការកែទម្រង់ជាច្រើន ដូចជា ការបញ្ចុះថ្លៃអគ្គិសនី, ការលើកកម្ពស់កិច្ចសម្រួលពាណិជ្ជកម្ម និង ការកាត់បន្ថយចំណាយផ្លូវការ និង មិនផ្លូវការ ក្នុងការធ្វើធុរកិច្ច ជាដើម ក្នុងគោលដៅលើកកម្ពស់បរិយាកាសអំណោយផលដល់ការធ្វើធុរកិច្ច ដើម្បីបង្កើនទំនុកចិត្ត និងទាក់ទាញវិនិយោគិន, ទាំងនៅក្នុង និង ក្រៅប្រទេស ។

### ទី២. បញ្ហាប្រឈម និង ហានិភ័យ ចំពោះការអភិវឌ្ឍកម្ពុជា

បច្ចុប្បន្ន, សេដ្ឋកិច្ចសកលកំពុងហ៊ុមព័ទ្ធដោយបញ្ហាជាច្រើន ដូចជា វិបត្តិនយោបាយនៅមជ្ឈិមបូព៌ា, ផលប៉ះពាល់ដែលកំពុងលេចឡើងកាន់តែច្បាស់ ពីការប្រែប្រួលអាកាសធាតុ, បញ្ហាពាក់ព័ន្ធនឹងភូមិសាស្ត្រនយោបាយ, ភេរវកម្ម និង សន្តិសុខ ។ល។ ទន្ទឹមនេះ, កំណើនសេដ្ឋកិច្ចតំបន់ និង ពិភពលោក បានបន្តថមថយ ដោយសារភាពរអាក់រអួលនៃច្រវាក់ផលិតកម្មសកល ដែលបណ្តាលមកពីភាពមិនច្បាស់លាស់នៃគោលនយោបាយពាណិជ្ជកម្មពិភពលោករបស់ប្រទេសធំៗមួយចំនួន ជាពិសេស ភាព-

តានតឹងនៃសង្គ្រាមពាណិជ្ជកម្មរវាងសហរដ្ឋអាមេរិក និង ចិន ។ បន្ថែមនេះ, សេដ្ឋកិច្ចកម្ពុជា ក៏ត្រូវប្រឈមនឹងហានិភ័យពីខាងក្រៅមួយចំនួនទៀត រួមទាំងលទ្ធភាពនៃការដក ឬ ព្យួរ EBA ផងដែរ ។ ជាមួយនឹងហានិភ័យខាងក្រៅ, សេដ្ឋកិច្ចកម្ពុជា ក៏បន្តប្រឈមនឹងបញ្ហា និង ហានិភ័យធំៗក្នុងស្រុកមួយ-ចំនួនទៀត ដូចជា ភាពមានកម្រិតនៃសមត្ថភាពប្រកួតប្រជែងខាងសេដ្ឋកិច្ច ហើយមូលដ្ឋាននៃកំណើនក៏នៅតូចចង្អៀតនៅឡើយ ទោះបីរាជរដ្ឋាភិបាលសម្រេចបាននូវលទ្ធផលល្អប្រសើរមួយចំនួនក៏ដោយ នៅក្នុងកិច្ចប្រឹងប្រែងធ្វើពិពិធកម្មសេដ្ឋកិច្ចជាតិ ក្នុងបណ្ដាឆ្នាំកន្លងទៅ ។ ជារួម, បញ្ហាប្រឈម និង ហានិភ័យ, ទាំងពីក្រៅ និង ក្នុងប្រទេសទាំងអស់នេះ, បាន និង កំពុង បង្កការគំរាមមកលើចីរភាព និង និរន្តរភាពនៃការអភិវឌ្ឍកម្ពុជា ។

### ទី៣. ទិសដៅអាទិភាពរបស់រាជរដ្ឋាភិបាល

ក្នុងបរិការណ៍ឆ្នាំ ២០២០ ដូចបានគូសរំលេចខាងលើ, រាជរដ្ឋាភិបាលបានគិតគូរជាយុទ្ធសាស្ត្រ ដោយឈរលើស្មារតីប្រុងប្រយ័ត្នខ្ពស់ តាមរយៈការដាក់ចេញនូវវិធានការគោលនយោបាយផ្សំចម្រុះ (Policy Mix) មួយចំនួន សំដៅ : (១). ស្រូបយកការប៉ះទង្គិច ដែលអាចកើតមានឡើងនៅក្នុងយថាហេតុអាក្រក់ណាមួយ; (២). ដោះស្រាយបញ្ហាជារចនាសម្ព័ន្ធ ដែលដាក់កម្រិតលើភាពប្រកួតប្រជែងនៃសេដ្ឋកិច្ចជាតិ; (៣). ពង្រឹងភាពធន់នឹងវិបត្តិ លើផ្នែកម៉ាក្រូសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសាធារណៈ; និង (៤). បង្កើនប្រសិទ្ធភាព និង ស័ក្តិសិទ្ធិភាព នៃស្ថាប័នសាធារណៈ ។

ជារួម, គោលដៅចម្បងនៃវិធានការគោលនយោបាយទាំងអស់នេះ គឺបន្តពង្រឹង និង ពង្រីកភាព-ប្រកួតប្រជែង ក៏ដូចជាជំរុញការធ្វើពិពិធកម្មសេដ្ឋកិច្ចជាតិ នៅក្នុងល្បឿន និង ជវភាពមួយកាន់តែខ្ពស់ថែមទៀត ព្រមទាំងបញ្ចៀសនូវហានិភ័យ ឬ កាត់បន្ថយឱ្យបានជាអតិបរមា នូវផលប៉ះពាល់អាក្រក់ពីការប៉ះទង្គិចណាមួយ ដែលអាចកើតមានឡើងជាយថាហេតុ ។

### ៤. វឌ្ឍនភាពសំខាន់ៗនៅក្នុងការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ដែលមានចក្ខុវិស័យប្រែក្លាយប្រព័ន្ធហិរញ្ញវត្ថុសា-ធារណៈកម្ពុជា ឆ្ពោះទៅរកឧត្ដមានុវត្តអន្តរជាតិ, បាន និង កំពុង ស្ថិតក្នុងដំណាក់កាល ទី ៣ ពោលគឺ ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ (ឆ្នាំ ២០១៦-២០២០) ដែលផ្ដោតលើការបង្កើត និង ការកែលម្អការផ្សារ

ភ្ជាប់រវាងថវិកា និង គោលនយោបាយ ព្រមទាំងការបន្តពង្រឹងសមិទ្ធផលនៃការកែទម្រង់ ពីដំណាក់កាលទាំង ២ កន្លងមក បន្ថែមទៀត ។

ក្នុងគោលដៅនេះ, នៅដើមឆ្នាំ ២០១៩, ក្រោមក្របខ័ណ្ឌនៃការអនុវត្ត **យុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិកា ២០១៨-២០២៥**, រាជរដ្ឋាភិបាលបានអនុម័តដាក់ចេញនូវយុទ្ធសាស្ត្រចំនួន ៣ សំដៅធានាចីរភាពនៃចំណូលរបស់រដ្ឋ និង ពង្រឹងជាប្រព័ន្ធ នូវប្រសិទ្ធភាពក្នុងការគ្រប់គ្រងថវិកាជាតិ រួមមាន : (១). **យុទ្ធ-សាស្ត្រកៀរគរចំណូល ២០១៩-២០២៣** ដែលផ្តោតលើការធ្វើទំនើបកម្មប្រព័ន្ធប្រមូលចំណូល, ការលើកកម្ពស់ការផ្តល់សេវា និង ការធានាកំណើនចំណូលប្រកបដោយចីរភាព; (២). **យុទ្ធសាស្ត្រនៃការកែ-ទម្រង់ប្រព័ន្ធថវិកាថ្នាក់ក្រោមជាតិឆ្នាំ ២០១៩-២០២៥** ដែលផ្តោតលើការលើកកម្ពស់ប្រសិទ្ធភាព, តម្លាភាព និង គណនេយ្យភាព នៃការគ្រប់គ្រងធនធានសាធារណៈ តាមរយៈការរៀបចំកែទម្រង់ថវិកាថ្នាក់ក្រោមជាតិ, ជាជំហានៗ, ឱ្យមានសង្គតិភាពខាងគោលការណ៍រៀបចំ និង អនុវត្ត និង ឱ្យមានភាពឆ្លើយឆ្លងប្រទាក់ក្រឡាគ្នាជាមួយថវិកាថ្នាក់ជាតិ, ពោលគឺ ការរៀបចំប្រព័ន្ធថវិកាថ្នាក់ជាតិ និង ប្រព័ន្ធថវិកាថ្នាក់ក្រោមជាតិ ឱ្យក្លាយជាប្រព័ន្ធថវិកាជាតិតែមួយ តាមរយៈការធ្វើសមាហរណកម្មផែនការនីយកម្ម និង ការតម្រឹមអាទិភាពនៃថវិកាថ្នាក់ក្រោមជាតិ ជាមួយនឹងអាទិភាពគោលនយោបាយតាមវិស័យនៃក្រសួង-ស្ថាប័ន ដើម្បីបម្រើឱ្យតម្រូវការជាក់ស្តែងនៃការអភិវឌ្ឍនៅតាមមូលដ្ឋាន; និង (៣). **យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈ ឆ្នាំ ២០១៩-២០២៥** ដែលផ្តោតលើការបង្កើនប្រសិទ្ធភាព, តម្លាភាព និង គណនេយ្យភាព ក្នុងការ-គ្រប់គ្រងកិច្ចប្រតិបត្តិការចំណាយថវិកា ពិសេស តាមរយៈការបង្កើនសិទ្ធិសម្រេច និង ការទទួលខុស-ត្រូវលើកិច្ចលទ្ធកម្ម ជាបណ្តើរៗ ជូនដល់ក្រសួង-ស្ថាប័ន, រដ្ឋបាលថ្នាក់ជាតិ និង អង្គភាពសាធារណៈប្រហាក់ប្រហែល ។

មួយផ្នែកទៀត, គម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ក៏ត្រូវបានបន្តពង្រឹង និង ពង្រីកវិសាលភាព, ទាំងក្នុងទិដ្ឋភាពនៃការអនុវត្តចំណាត់ថ្នាក់ថវិកា និង ក្នុងទិដ្ឋភាពនៃការគ្របដណ្តប់លើស្ថាប័ន និង ភ្នាក់ងារចំណាយរបស់រាជរដ្ឋាភិបាល, ឱ្យស្របតាមស្តង់ដាអន្តរជាតិ ដើម្បីធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងថវិកា និង លំហូរសាច់ប្រាក់ ។ ក្នុងនោះ, នៅឆ្នាំ ២០១៨, ក្រសួង-ស្ថាប័ន ចំនួន ១០ ត្រូវបានដាក់ឱ្យប្រើប្រាស់ FMIS ជាផ្លូវការ, ហើយនៅឆ្នាំ ២០១៩ គម្រោងនេះ បានគ្រសោបបញ្ចូលនូវក្រសួង-ស្ថាប័ន ចំនួន ១០ ថ្មីបន្ថែម ព្រមទាំងមន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នៅតាមរាជធានី-ខេត្ត ទាំង

២៥ ។ នៅឆ្នាំ ២០២០ ខាងមុខ, យើងគ្រោងនឹងដាក់បញ្ចូលក្រសួង-ស្ថាប័ន ចំនួន ១៧ ថ្មី បន្ថែមទៀត ។ ជាមួយគ្នានេះ, ការអនុវត្តថវិកាកម្មវិធី ក៏ត្រូវបាន និង កំពុងដាក់ ឱ្យអនុវត្តនៅគ្រប់ក្រសួង-ស្ថាប័ន និង គ្រប់រាជធានី-ខេត្ត ដើម្បីពង្រឹងការគ្រប់គ្រងថវិកា ឱ្យមានប្រសិទ្ធភាពខ្ពស់ ។

ខ្ញុំសូមគូសបញ្ជាក់ផងដែរថា ឆ្នាំ ២០២០ គឺជាឆ្នាំដំបូងនៃការអនុវត្តសាកល្បង **ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម ២០២០-២០២២ (MTFF) និង ក្របខ័ណ្ឌថវិការយៈពេលមធ្យម ២០២០-២០២២** (MTBF) ។ ក្របខ័ណ្ឌថ្មីនេះ មានរួមបញ្ចូលនូវការកំណត់ពិដានចំណាយ និង ការបែងចែកធនធានថវិកា បម្រើឱ្យគោលបំណងគោលនយោបាយរបស់ក្រសួង-ស្ថាប័ន ដើម្បីធានាឱ្យបាននូវចីរភាពសារពើពន្ធ តាមរយៈការលើកកម្ពស់វិន័យថវិកា និង ប្រសិទ្ធភាពចំណាយ ព្រមទាំងការបង្កើនការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយអាទិភាពតាមវិស័យ ។ ក្នុងន័យនេះ, **ក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈឆ្នាំ ២០២០** ត្រូវបានរៀបចំឡើងនៅក្នុង **ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម ២០២០-២០២២** ដែលមានចរិតជាការគិតគូរវែងឆ្ងាយប្រកបដោយការប្រុងប្រយ័ត្នខ្ពស់ តាមរយៈការអនុវត្តគោលនយោបាយថវិកាជំរុញកំណើន (Stimulus Budget) និង ការដាក់ចេញនូវគោលនយោបាយម៉ាក្រូហិរញ្ញវត្ថុប្រយ័ត្នប្រយែង ។ ខ្ញុំរំលេចបន្ថែមថា នៅក្របខ័ណ្ឌនេះ, អាទិភាពដ៏ចម្បងមួយរបស់រាជរដ្ឋាភិបាល, ក្នុងចំណោមបណ្តាអាទិភាពសំខាន់ៗនៃក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម, គឺការបន្តផ្តោតការយកចិត្តទុកដាក់ដល់ការលើកកម្ពស់ជីវភាពរបស់មន្ត្រីរាជការគ្រប់ប្រភេទ ឱ្យកាន់តែប្រសើរឡើងជាលំដាប់ថែមទៀត ។ ក្នុងស្មារតីនេះ, សម្រាប់ឆ្នាំ ២០២០ និង រយៈពេលមធ្យមខាងមុខ, បៀវត្សអប្បបរមាសរុបប្រចាំខែ របស់មន្ត្រីរាជការ និង កងកម្លាំងប្រដាប់អាវុធ ម្នាក់ៗ នឹងត្រូវបានគ្រោងឱ្យមានកំណើនជាមធ្យម ក្នុងរង្វង់ ៧% ក្នុងមួយឆ្នាំ ព្រមជាមួយនឹងការបន្តផ្តល់អាទិភាព លើការអនុវត្តគោលនយោបាយគាំពារសង្គម, ទាំងផ្នែកប្រព័ន្ធសន្តិសុខសង្គម និង ប្រព័ន្ធជំនួយសង្គម ។

***សម្តេច, ឯកឧត្តម, លោកជំទាវ, សមាជិក-សមាជិកា នៃព្រឹទ្ធសភា និង រដ្ឋសភា !***

សរុបសេចក្តីមកវិញ, សភាពការណ៍រួមនាបច្ចុប្បន្ន និង ទស្សនវិស័យសម្រាប់រយៈពេលមធ្យមទៅមុខ តម្រូវឱ្យរាជរដ្ឋាភិបាលបន្តផ្តោតអាទិភាពនៃគោលនយោបាយសង្គម-សេដ្ឋកិច្ចរបស់ខ្លួន លើ : (ទី១). ការពង្រឹងភាពរឹងមាំ, ភាពធន់នឹងវិបត្តិ និង បរិយាប័ន្ននៃកំណើនសេដ្ឋកិច្ច ពិសេស ការបង្កើនការងារសមរម្យជូនដល់ប្រជាពលរដ្ឋ តាមរយៈការពង្រឹងប្រភពមូលដ្ឋានកំណើនដែលមានស្រាប់ផង និង ការបង្កើតប្រភព

កំណើនថ្មីបន្ថែមទៀតផង; និង **(ទី២)**• ការពង្រឹងការអភិវឌ្ឍប្រព័ន្ធគាំពារសង្គម និង ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ដើម្បីបន្តលើកស្ទួយជីវភាពរស់នៅរបស់ប្រជាជន និង គាំទ្រដល់កំណើនសេដ្ឋកិច្ច ។ ដើម្បីគោលដៅនេះ, គ្រប់ស្ថាប័នរដ្ឋត្រូវប្រឹងប្រែងកាន់តែសកម្មឡើងថែមទៀត, តាមរយៈការសហការគ្នាជាធ្លុងមួយ, ក្នុងការអនុវត្តប្រកបដោយប្រសិទ្ធភាពខ្ពស់ នូវបណ្តាវិធានការកែទម្រង់មុតស្រួច និង ស៊ីជម្រៅទាំងឡាយ, ជាមួយនឹងឆន្ទៈនយោបាយប្តូរផ្តាច់ និង ការទទួលខុសត្រូវខ្ពស់, សំដៅពង្រឹងភាពប្រកួតប្រជែងនៃសេដ្ឋកិច្ចជាតិ ព្រមទាំងពន្លឿនកិច្ចការកែទម្រង់ និង ពង្រឹងសមត្ថភាពស្ថាប័នសាធារណៈ ឱ្យក្លាយជាប្រព័ន្ធរដ្ឋបាលសាធារណៈមួយ កាន់តែស្អាតស្អំ, កាន់តែឆ្លាតវៃ និង កាន់តែមានសមត្ថភាពខ្លាំងពូកែ ដើម្បីអាចដោះស្រាយបញ្ហាសង្គម និង សេដ្ឋកិច្ច ដោយជោគជ័យ សម្រាប់ទ្រទ្រង់ដល់ការផ្លាស់ប្តូររចនាសម្ព័ន្ធសេដ្ឋកិច្ច និង សង្គមកម្ពុជា ក្នុងរយៈពេលវែងទៅមុខ ។

ក្នុងស្មារតីនេះ, រាជរដ្ឋាភិបាលបានត្រៀមនូវវិធានការ និង កញ្ចប់ថវិកាអន្តរាគមន៍សម្រាប់ដោះស្រាយ និង ទប់ទល់គ្រប់សភាពការណ៍ និង ហានិភ័យនានា ជាយថាហេតុ, ដែលមិនត្រឹមតែសំដៅធានាឱ្យបាននូវសុខសន្តិភាព និង ស្ថិរភាព ជារួមប៉ុណ្ណោះទេ, ប៉ុន្តែ ថែមទាំងជួយធានាចីរភាពកំណើនសេដ្ឋកិច្ចជាតិផងដែរ ។ ទាំងនេះ គឺជាមូលដ្ឋានចាំបាច់មិនអាចខ្វះបាន សម្រាប់ការបង្កើតការងារប្រកបដោយគុណភាពជូនដល់ពលករកម្ពុជា ពិសេសជូនដល់ស្រទាប់យុវវ័យ, សម្រាប់ការបង្កើនចំណូល និង ការលើកស្ទួយកម្រិតជីវភាពរបស់ប្រជាជនទូទាំងប្រទេស, ព្រមទាំងសម្រាប់ធានាឱ្យកម្ពុជាអាចឈានទៅសម្រេចបាននូវចក្ខុវិស័យនៃការអភិវឌ្ឍវែងឆ្ងាយរបស់ខ្លួន ពោលគឺ ការសម្រេចបាននូវឋានៈជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់ នៅឆ្នាំ ២០៣០ និង ឋានៈជាប្រទេសចំណូលខ្ពស់ នៅឆ្នាំ ២០៥០ ។

មុននឹងបញ្ចប់, ខ្ញុំសូមជម្រាបជូនអង្គសិក្ខាសាលាជ្រាបផងដែរថា ៖ ដូចឆ្នាំមុនៗ, បន្ទាប់ពីបទបង្ហាញរបស់ឯកឧត្តម រដ្ឋលេខាធិការប្រចាំការ **វង្សី វិស្សុត** និង សហការី, ថ្នាក់ដឹកនាំកម្រិតនយោបាយ និង កម្រិតជំនាញ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលមានវត្តមាននៅទីនេះ, រួមមាន ឯកឧត្តម និង លោកជំទាវ ជារដ្ឋលេខាធិការ និង អនុរដ្ឋលេខាធិការ ព្រមទាំងមន្ត្រីជំនាញជាន់ខ្ពស់ពាក់ព័ន្ធ, នឹងត្រៀមខ្លួនផ្តល់ការបំភ្លឺ ចំពោះរាល់សំណួរផ្សេងៗ តាមតម្រូវការចាំបាច់ជាក់ស្តែង ព្រមទាំងទន្ទឹងរង់ចាំទទួលនូវមតិយោបល់ និង អនុសាសន៍ល្អៗ ក្នុងន័យស្ថាបនា ពីអង្គសិក្ខាសាលា ដោយក្តីរីករាយ ។

ជាថ្មីម្តងទៀត, ខ្ញុំសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ជូនចំពោះ **សម្តេចអគ្គមហា-ពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា** ដែលបានគាំទ្រការរៀបចំសិក្ខាសាលានេះ និង ឆ្លៀតពេលដ៏មានតម្លៃ អញ្ជើញចូលរួមថ្លែងសុន្ទរកថាក្នុងកម្មវិធីបើកសិក្ខាសាលា នាព្រឹកនេះ ។

ជាចុងក្រោយ, ខ្ញុំសូមជូនពរឱ្យសិក្ខាសាលាថ្ងៃនេះ ប្រព្រឹត្តទៅប្រកបដោយជោគជ័យ និង សូមគោរពជូនពរ **សម្តេចអគ្គមហាពញាចក្រី,** ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី, ទាំងអស់ ដែលមានវត្តមាននៅទីនេះ, សូមប្រកបដោយពុទ្ធពរទាំង ៤ ប្រការ គឺ អាយុ, វណ្ណៈ, សុខៈ និង ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

**ខ្ញុំសូមអរគុណចំពោះការយកចិត្តទុកដាក់ !**